Australian Government

Fair Work OMBUDSMAN

# បញ្ជីឆែកមើលការងាររបស់ខ
# My employment checklist

អ្នកធ្វើការទាំងអស់នៅក្នុងប្រទេសអូស្ត្រាលីទទួលនូវសិទ្ធិបឋម។ សិទ្ធិទទួលទាំងនេះមានរួមទាំងសិទ្ធិទទួលលក្ខខណ្ឌនិងបៀវត្សរ៍ទាបបំផុត សម្រាប់ការងារទាំងអស់ដែលលោកអ្នកធ្វើ។

## តើ Fair Work Ombudsman ជាអ្នកណា?

Fair Work Ombudsman ការពារនិងពង្រឹងសិទ្ធិនិងសិទ្ធិទទួលនៅកន្លែងការងាររបស់លោកអ្នក។ យើងខ្ញុំគឺជាស្ថាប័នរបស់រដ្ឋាភិបាលអូស្ត្រាលី ហើយតួនាទីរបស់យើងខ្ញុំមានរួមទាំងការជួយនិយោជិត និយោជក អ្នកម៉ៅការនិងសហគមន៍ ឲ្យយល់ដឹងនិងអនុវត្តតាមច្បាប់ការងារនៃប្រទេសអូស្ត្រាលី។

## តើខ្ញុំគួរទាក់ទង Fair Work Ombudsman នៅពេលណា??

សូមទាក់ទងយើងខ្ញុំដើម្បីទទួលព័ត៌មាននិងឱវាទ បើលោកអ្នកមានសំណួរណាមួយអំពីស្ថានភាពការងាររបស់លោកអ្នក ឬបើលោកអ្នកជឿថា លោកអ្នកមិនទទួលលក្ខខណ្ឌនិងបៀវត្សរ៍ទាបបំផុតទេនោះ។ យើងខ្ញុំអាចឆ្លើយសំណួរលោកអ្នកដោយរក្សាការសម្ងាត់ ហើយសេវាយើងខ្ញុំមិនគិតថ្លៃសម្រាប់ពលរដ្ឋទាំងអស់។

## តើបញ្ជីឆែកមើលនេះជួយខ្ញុំយ៉ាងណាដែរ?

ដឹងអំពីសិទ្ធិនិងសិទ្ធិទទួលនៅកន្លែងការងាររបស់លោកអ្នក តាមរយៈការបំពេញបញ្ជីឆែកមើលនេះ។ សូមគូសព័ទ្ធជុំវិញចម្លើយសម្រាប់សំណួរនីមួយៗនៅខាងក្រោមនេះ។ លោកអ្នកអាចទទួលចម្លើយនៃសំណួរដែលលោកអ្នកគូសព័ទ្ធជុំវិញ 'ទេ' ឬ 'មិនប្រាកដ' (?) តាមរយៈការសាកសួរនិយោជកលោកអ្នក ការទូរសព្ទទាក់ទង Fair Work Infoline តាមលេខ 13 13 94 ឬការបើកមើលអ៊ីនធើណិត www.fairwork.gov.au

## តើខ្ញុំដឹងឬទេនូវ៖

- ពេញស្របច្បាប់នៃនិយោជករបស់ខ្ញុំ? បាទឬចាស / ទេ / ?
- ឈ្មោះនាយក / ប្រធានរបស់ខ្ញុំ? បាទឬចាស / ទេ / ?
- មុខតំណែងនៃការងាររបស់ខ្ញុំ? បាទឬចាស / ទេ / ?
- ការងារអ្វីទៅដែលគេតម្រូវឲ្យខ្ញុំបំពេញ? បាទឬចាស / ទេ / ?
- ឈ្មោះនៃលក្ខខណ្ឌបៀវត្សរ៍និងការងារ (award) ឬកិច្ចព្រមព្រៀង (agreement) សម្រាប់ការប្រកបការងាររបស់ខ្ញុំ? បាទឬចាស / ទេ / ?
- របៀបដែលស្តង់ដារការងារជាតិ (National Employment Standards - NES) អនុវត្តសម្រាប់ខ្លួនខ្ញុំ? បាទឬចាស / ទេ / ?

## តើខ្ញុំបាន៖

- បំពេញសេចក្តីប្រកាសលេខពន្ធដារឬទេ? បាទឬចាស / ទេ / ?
- ចុះហត្ថលេខាលើកិច្ចសន្យា (contract) ឬកិច្ចព្រមព្រៀង (agreement) ណាមួយឬទេ? បាទឬចាស / ទេ / ?
- បានទទួលកិច្ចសន្យាឬកិច្ចព្រមព្រៀងមួយច្បាប់ឬទេ? បាទឬចាស / ទេ / ?
- បានទទួលរបាយការណ៍ព័ត៌មានការងារមានយុត្តិធម៌ (Fair Work Information Statement) (បើចាប់ផ្តើមការងារនៅថ្ងៃ ឬក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2010)? បាទឬចាស / ទេ / ?

## តើខ្ញុំដឹងថាតើខ្ញុំ៖

- ជាបុគ្គលិកធ្វើការពេញពេល មិនពេញពេល ឬម្តងម្កាល? បាទឬចាស / ទេ / ?
- ជាបុគ្គលិកអចិន្ត្រៃយ៍ឬបណ្តោះអាសន្ន? បាទឬចាស / ទេ / ?
- ជាបុគ្គលិកហាត់ការ (probation) និងដឹងនូវពេលបញ្ចប់អំឡុងពេលហាត់ការឬទេ? បាទឬចាស / ទេ / ?
- កំពុងធ្វើការក្នុងអំឡុងពេលសាកល្បង (trial) ឬទេ? បាទឬចាស / ទេ / ?
- កំពុងទទួលបៀវត្សរ៍សម្រាប់អំឡុងពេលសាកល្បងឬទេ? បាទឬចាស / ទេ / ?
- ទទួលបៀវត្សរ៍ដើម្បីចូលរួមក្នុងការប្រជុំឬទេ? បាទឬចាស / ទេ / ?
- ទទួលបៀវត្សរ៍ដើម្បីធ្វើការមុនម៉ោងឬចេញក្រោយម៉ោងនៅក្រៅវេនពេលម៉ោងផ្លូវការឬទេ? បាទឬចាស / ទេ / ?
- កំពុងទទួលបៀវត្សរ៍សម្រាប់ការបណ្តុះបណ្តាលឬទេ? បាទឬចាស / ទេ / ?
- ត្រូវសងប្រាក់ បើអតិថិជនចេញពីហាងដោយមិនបានបង់ប្រាក់ ចំនួនសាច់ប្រាក់តិចជាងចំនួនបូកសរុបដោយម៉ាស៊ីនគិតលេខ ឬខ្ញុំធ្វើឲ្យបែកបាក់អ្វីមួយ? បាទឬចាស / ទេ / ?
- ត្រូវបង់ប្រាក់សម្រាប់គ្រោះថ្នាក់ឬការធានារ៉ាប់រងនៅពេលបើកបររថយន្តនិយោជករបស់ខ្ញុំឬទេ? បាទឬចាស / ទេ / ?
- ជាអ្នកហាត់ធ្វើកូនជាង (apprentice) ឬអ្នកទទួលការបណ្តុះបណ្តាល (trainee)? បាទឬចាស / ទេ / ?
- មានកិច្ចសន្យាបណ្តុះបណ្តាលចុះបញ្ជីត្រឹមត្រូវឬទេ? បាទឬចាស / ទេ / ?
- កំពុងទទួលប្រាក់សោធននិវត្តន៍ឬទេ (superannuation)? បាទឬចាស / ទេ / ?

## តើខ្ញុំ៖

- ស្លៀកពាក់ឯកសណ្ឋានឬទេ? បាទឬចាស / ទេ / ?
- បង់ថ្លៃឯកសណ្ឋានឬទេ? បាទឬចាស / ទេ / ?
- បោកគក់ឯកសណ្ឋានឬទេ? បាទឬចាស / ទេ / ?
- ទទួលឯកសណ្ឋានឬប្រាក់ឧបត្ថម្ភសម្រាប់ការបោកគក់ឬទេ? បាទឬចាស / ទេ / ?
- ផ្គត់ផ្គង់ដោយខ្លួនឯងនូវប្រដាប់ប្រដារជាងប្រើប្រាស់? បាទឬចាស / ទេ / ?
- ទទួលប្រាក់ឧបត្ថម្ភសម្រាប់ប្រដាប់ប្រដារជាងប្រើប្រាស់ឬទេ? បាទឬចាស / ទេ / ?
- ទទួលក្រដាសជូនដំណឹងអំពីបៀវត្សរ៍សម្រាប់រាល់បៀវត្សរ៍ដែលទទួលឬទេ? បាទឬចាស / ទេ / ?

## តើក្រដាសជូនដំណឹងអំពីបៀវត្សរ៍របស់ខ្ញុំមានរួមបញ្ចូលនូវ៖

- ឈ្មោះខ្ញុំឬទេ? បាទឬចាស / ទេ / ?
- ឈ្មោះនិយោជកខ្ញុំឬទេ? បាទឬចាស / ទេ / ?
- លេខ ABN របស់និយោជកខ្ញុំ (ចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2010) ឬទេ? បាទឬចាស / ទេ / ?
- ថ្ងៃខែឆ្នាំចាប់ផ្តើមនិងថ្ងៃបញ្ចប់នៃអំឡុងពេលបៀវត្សរ៍ព្រមទាំងថ្ងៃបើកប្រាក់ឬទេ? បាទឬចាស / ទេ / ?
- អត្រាបៀវត្សរ៍ឬទេ? បាទឬចាស / ទេ / ?
- ប្រាក់បន្ថែមពេលធ្វើការក្រៅម៉ោងធម្មតា (loadings) និង / ឬប្រាក់បន្ថែមពេលធ្វើការនៅចុងសប្តាហ៍ឬថ្ងៃឈប់សម្រាកសាធារណៈ (penalties) ឬទេ? បាទឬចាស / ទេ / ?
- ប្រាក់សម្រាប់ពេលធ្វើការលើសម៉ោងធម្មតាឬទេ? បាទឬចាស / ទេ / ?

- ចំនួនប្រាក់កាត់ចេញដែលខ្ញុំបានយល់ព្រមឬទេ? បាទឬចាស / ទេ / ?
- ចំនួនប្រាក់ក្រោយបង់ពន្ធ និងមុនបង់ពន្ធឬទេ? បាទឬចាស / ទេ / ?
- វិភាគទាននៃប្រាក់សំរាប់ពេលចូលនិវត្តន៍ណាមួយ, រួមមានចំនួនប្រាក់ដែលបានបើកឲ្យ, ថ្ងៃខែឆ្នាំដែលប្រាក់នេះបានបើកឲ្យហើយនិងឈ្មោះនិងលេខនៃមូលនិធិនៃប្រាក់សំរាប់ពេលចូលនិវិត្តន៍? បាទឬចាស / ទេ / ?

## តើខ្ញុំដឹងនូវ៖

- អត្រាបៀវត្សរ៍ក្នុងមួយម៉ោង មុនបង់ពន្ធឬទេ? បាទឬចាស / ទេ / ?
- ប្រាក់បន្ថែមសម្រាប់បុគ្គលិកម្តងម្កាល (casual loading) (បើត្រូវអនុវត្ត)? បាទឬចាស / ទេ / ?
- ពេលបើកបៀវត្សរ៍ម្តងៗ (ប្រចំាអាទិត្យ ពីរអាទិត្យម្តង ប្រចំាខែ) ឬទេ? បាទឬចាស / ទេ / ?
- វិធីបើកប្រាក់ (សាច់ប្រាក់ សែក បង់ចូលក្នុងគណនីធនាគាររបស់ខ្ញុំ)ឬទេ? បាទឬចាស / ទេ / ?
- ម៉ោងចាប់ផ្តើមនិងម៉ោងបញ្ចប់ឬទេ? បាទឬចាស / ទេ / ?
- ចំនួនម៉ោងធ្វើការតិចបំផុតសម្រាប់អាទិត្យនីមួយៗឬទេ? បាទឬចាស / ទេ / ?
- ថ្ងៃនិងម៉ោងវេន (rostered) ធ្វើការឬទេ? បាទឬចាស / ទេ / ?
- ម៉ោងបរិភោគអាហារ និងម៉ោងសម្រាកឬទេ? បាទឬចាស / ទេ / ?

## តើខ្ញុំដឹងកិច្ចការត្រូវធ្វើឬទេ បើ៖

- ខ្ញុំមានជំងឺនិងត្រូវការពេលឈប់សម្រាក? បាទឬចាស / ទេ / ?
- ខ្ញុំចង់បានវិស្សមកាល? បាទឬចាស / ទេ / ?
- ខ្ញុំត្រូវបំពេញកិច្ចការជាសមាជិកក្រុមវិនិច្ឆ័យទោសនៅតុលាការ? បាទឬចាស / ទេ / ?
- ខ្ញុំរងរបួសនៅកន្លែងធ្វើការ? បាទឬចាស / ទេ / ?
- ខ្ញុំចង់ធ្វើបណ្តឹងអំពីការរើសអើង ការសម្លុតធ្វើបាប (bullying) ឬការយាយីរំខាន? បាទឬចាស / ទេ / ?
- ខ្ញុំចង់បានការឈប់សម្រាកសម្រាប់មាតាឬបិតាថែទាំកូន? បាទឬចាស / ទេ / ?
- ខ្ញុំចង់បានការឈប់សម្រាកសម្រាប់សេវាសហគមន៍? បាទឬចាស / ទេ / ?
- ខ្ញុំចង់បានការឈប់សម្រាកសម្រាប់ពេលមានទុក្ខលំបាក? បាទឬចាស / ទេ / ?
- ខ្ញុំចង់ឈប់ធ្វើការ? បាទឬចាស / ទេ / ?
- ខ្ញុំត្រូវបានបណ្តេញចេញពីការងារ? បាទឬចាស / ទេ / ?
- ខ្ញុំត្រូវតែធ្វើអ្វីមួយដើម្បីដោះស្រាយផលប៉ះពាល់នៃអំពើហឹង្សាក្នុងគ្រួសារ និងតាមផ្ទះ ហើយវាមិនមានប្រសិទ្ធភាពក្នុងការធ្វើដូច្នេះបានទេ នៅក្រៅម៉ោងធ្វើការធម្មតារបស់ខ្ញុំ? បាទឬចាស / ទេ /

## កំណត់សម្គាល់

## ទាក់ទងយើងខ្ញុំ

**www.fairwork.gov.au**

Fair Work Infoline: **13 13 94**

**ត្រូវការជំនួយភាសាឬទេ?**

សូមទាក់ទងសេវាបកប្រែភាសា (TIS) តាមទូរសព្ទលេខ 13 14 50

**ជំនួយផ្នែកស្តាប់និងនិយាយ**

ទូរសព្ទតាមរយៈ National Relay Service (NRS)

- TTY: ទូរសព្ទទៅលេខ 1800 555 677 និងសុំឲ្យភ្ជាប់ទៅលេខ 13 13 94
- Speak & Listen: ទូរសព្ទទៅលេខ 1800 555 727 និងសុំឲ្យភ្ជាប់ទៅលេខ 13 13 94
- Internet relay: បើកអ៊ីនធើណិត www.relayservice.com.au និងសុំឲ្យភ្ជាប់ទៅលេខ 13 13 94



**ការមិនទទួលខុសត្រូវ**

Fair Work Ombusman ប្តេជ្ញាផ្តល់លោកអ្នកនូវឱវាទដែលលោកអ្នកអាចទុកចិត្តបាន។ ព័ត៌មានដែលមាននៅក្នុងក្រដាសផ្តល់ព័ត៌មាននេះគឺជាព័ត៌មានទូទៅ។ ប្រសិនបើលោកអ្នកមិនប្រាកដថាព័ត៌មាននេះ អនុវត្តលើស្ថានភាពរបស់លោកអ្នកយ៉ាងម៉េចនោះ លោកអ្នកអាចទូរស័ព្ទទៅខ្សែទូរស័ព្ទផ្តល់ព័ត៌មានតាមលេខ 13 13 94 ឬនិយាយជាមួយសហជីព, សមាគមឧស្សាហកម្ម ឬអ្នកមានវិជ្ជាជីវៈខាងទំនាក់ទំនងនៅកន្លែងការងារ។